ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ...១៣១ សស.ខម

ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល
## និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
## ជម្រាបជូន
## ឯកឧត្តម លោកជំទាវប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត

**កម្មវត្ថុ** ៖ ការលើកលែងកាតព្វកិច្ចពាក់ម៉ាស់នៅទូទាំងប្រទេស ដែលនៅទីសាធារណៈ ដែលជាទីលំហ ឬទីកន្លែងដែលមានចរន្តខ្យល់ចេញចូលល្អ និងការចូលរួមចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងគោលដៅបន្តធានានូវនិរន្តរភាពនៃភាពរឹងមាំនៃភាពស៊ាំសហគមន៍ និងការលើកលែងនូវកាតព្វកិច្ចពាក់ម៉ាស់។

**យោង** ៖ សារសម្លេងពិសេសស្តីពីការសម្រេចលើកលែងកាតព្វកិច្ចពាក់ម៉ាស់នៅទូទាំងប្រទេស ដែលនៅទីសាធារណៈ ដែលជាទីលំហ ឬទីកន្លែងដែលមានចរន្តខ្យល់ចេញចូលល្អ និងចំណាប់អារម្មណ៍ឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ លើរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំបន្ទាន់របស់គណៈប្រចាំការនៃ គ.ប.ក. នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ទាំងអស់ មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានសម្រេចលើកលែងនូវកាតព្វកិច្ចពាក់ម៉ាស់នៅទូទាំងប្រទេស សម្រាប់ទីសាធារណៈដែលជាទីលំហ ឬទីកន្លែងដែលមានចរន្តខ្យល់ចេញចូលល្អ។ ដូច្នេះ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាលសូមស្នើដល់គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងអាជ្ញាធររាជធានី-ខេត្ត ត្រូវធ្វើការណែនាំដល់សាធារណជនទាំងអស់នៅក្នុងភូមិសាស្ត្រស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អំពីការលើកលែងកាតព្វកិច្ចពាក់ម៉ាស់ និងការបន្តអនុវត្តវិធានការចាំបាច់នានា ដូចខាងក្រោម៖

១. ប្រជាជនទាំងអស់នៅទូទាំងប្រទេស ពុំតម្រូវឱ្យពាក់ម៉ាស់ទៀតឡើយនៅទីសាធារណៈដែលជាទីលំហ ឬទីកន្លែងដែលមានចរន្តខ្យល់ចេញចូលល្អ (ដូចជា នៅផ្លូវ ឬសួនច្បារសាធារណៈ អគារ ឬបន្ទប់បើកបង្អួច ឬផ្សារទំនើបធំៗដែលមានប្រព័ន្ធវំហូរខ្យល់ចេញចូលល្អ ជាដើម) ដោយប្រជាជនទាំងអស់អាចជ្រើសរើសដោយខ្លួនឯងពីការបន្តពាក់ម៉ាស់ ឬមិនពាក់ម៉ាស់។ ប៉ុន្តែការពាក់ម៉ាស់នេះ ត្រូវបានលើកទឹកចិត្តឱ្យបន្តអនុវត្តនៅពេលមានការចូលរួមក្នុងព្រឹត្តិការណ៍ជួបជុំ ទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ចនានាដែលមានការប្រមូលផ្តុំមនុស្សច្រើនកុះករកកកុញ (ជាអាទិ៍ ការរៀបចំសន្និសីទ កិច្ចប្រជុំ សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលផ្សេងៗ) និងទីតាំងបិទជិតនានាដែលពុំមានប្រព័ន្ធវំហូរខ្យល់ចេញចូលល្អ ឬទីកន្លែងដែលមានការសង្ស័យថាមានបុគ្គលដែលពាក់ព័ន្ធនឹងជំងឺកូវីដ-១៩។ ចំពោះទីតាំងបិទជិត ត្រូវបន្តអនុវត្តកាតព្វកិច្ចពាក់ម៉ាស់ ឬការពាក់ម៉ាស់ជាជម្រើស ដោយផ្អែកទៅតាមការកំណត់នៅក្នុង



ទីស្តីការក្រសួងសុខាភិបាល អគារលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

គោលការណ៍ប្រតិបត្តិស្តង់ដារនានា (SOPs) ដែលក្រសួង-ស្ថាប័នមានសមត្ថកិច្ចបានដាក់ចេញនាពេលកន្លងមក។ ប៉ុន្តែ កាតព្វកិច្ចពាក់ម៉ាសនេះ ត្រូវបន្តអនុវត្តសម្រាប់អ្នកជំងឺកូវីដ-១៩ និងអ្នកដែលមានការពាក់ព័ន្ធនឹងអ្នកវិជ្ជមានកូវីដ-១៩។

២. គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងអាជ្ញាធររាជធានី-ខេត្ត ត្រូវបន្តអប់រំនិងជំរុញលើកទឹកចិត្តប្រជាជនទាំងអស់ដែលគ្រប់អាយុចាក់វ៉ាក់សាំងកូវីដ-១៩ ហើយបានចាក់ដូសមូលដ្ឋានពេញលេញរួច ឱ្យចូលរួមចាក់វ៉ាក់សាំងដូសទី៣ ដែលត្រូវបានកំណត់ជាដូសអប្បបរមាសម្រាប់ប្រជាជនទូទៅនៅក្នុងប្រទេសកម្ពុជា។ ការចូលរួមនេះត្រូវបានចាត់ទុកជាកាតព្វកិច្ចផ្នែកស្មារតីរបស់ប្រជាពលរដ្ឋគ្រប់រូប ក្នុងការរក្សាសុខុមាលភាពផ្ទាល់ខ្លួន ការពារអាយុជីវិតខ្លួនឯងនិងក្រុមគ្រួសារ ព្រមទាំងរួមចំណែកជាមួយរាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងគោលដៅបន្តធានានូវនិរន្តរភាពនៃភាពរឹងមាំនៃភាពស៊ាំសហគមន៍ និងការលើកលែងនូវកាតព្វកិច្ចពាក់ម៉ាស់។

៣. គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងអាជ្ញាធររាជធានី-ខេត្ត ត្រូវចូលរួមអនុវត្តសេចក្តីសម្រេចស្តីពីការធ្វើសមាហរណកម្មការព្យាបាលអ្នកជំងឺកូវីដ-១៩ នៅក្នុងប្រព័ន្ធថែទាំព្យាបាលតែមួយ (ការរៀបចំបន្ទប់ដាច់ដោយឡែក និងការរៀបចំរំហូរអ្នកជំងឺត្រឹមត្រូវ) នៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន និងបន្តយកចិត្តទុកដាក់ត្រៀមលក្ខណៈពង្រឹងសមត្ថភាពឆ្លើយតបរបស់ប្រព័ន្ធសុខាភិបាល តាមរយៈការបន្តត្រៀមក្រុមការងារឆ្លើយតបបន្ទាន់ ក្រុមគ្រូពេទ្យព្យាបាល គ្រែសង្គ្រោះបន្ទាន់ សម្ភារៈបរិក្ខារពេទ្យ និងឱសថព្យាបាលជំងឺកូវីដ-១៩ រួមទាំងឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដើម្បីអាចឆ្លើយតបបានទាន់ពេលវេលា ទៅនឹងសភាពការណ៍ហានិភ័យណាមួយដែលអាចកើតមានឡើងដោយថាហេតុ។ ជាមួយគ្នានេះ អ្នកផ្តល់សេវាក្នុងវិស័យសាធារណៈ និងឯកជន ព្រមទាំងប្រជាជនទាំងអស់ ត្រូវចូលរួមគោរពនិងអនុវត្តនូវវិធានការសុខាភិបាល និងវិធានការរដ្ឋបាលជាធរមាន ហើយក៏ត្រូវប្រញាប់ធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយខ្លួនឯង ក្នុងករណីមានការសង្ស័យ ដូចជាមានរោគសញ្ញាក្តៅខ្លួន ក្អក ឬរោគសញ្ញាផ្លូវដង្ហើមផ្នែកខាងលើ (តឹងច្រមុះ ហៀរសំបោរ រមាស់ក ស្អកក ឈឺក ជាដើម) និងដាក់ខ្លួននៅដាច់ដោយឡែកព្យាបាលនៅតាមផ្ទះក្នុងករណីមានជំងឺកូវីដ-១៩ កម្រិតស្រាល ស្របតាមគោលការណ៍ប្រតិបត្តិស្តង់ដារដែលមានជាធរមាន ព្រមទាំងត្រូវចូលរួមសហការ និងរាយការណ៍ពីករណីសង្ស័យដែលអាចនាំឱ្យមានការផ្ទុះឡើងវិញនៃការឆ្លងវីរុសកូវីដ-១៩ ជូនដល់មន្ទីរសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច។

៤. មន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានី-ខេត្ត នីមួយៗ ត្រូវធ្វើរបាយការណ៍ប្រចាំថ្ងៃពីករណីវិជ្ជមានកូវីដ-១៩ ដែលរកឃើញចាប់ពីចាប់ផ្តើមអនុវត្តការលើកលែងកាតព្វកិច្ចពាក់ម៉ាស់នេះ រហូតដល់មានការណែនាំជាថ្មីទៀត ជូនដល់គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជធានី-ខេត្ត រៀងៗខ្លួន និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង នៃក្រសួងសុខាភិបាល ដែលនាយកដ្ឋាននេះ នឹងត្រូវផ្តល់ទិន្នន័យពាក់ព័ន្ធជូនទៅអនុគណៈកម្មការវាយតម្លៃ ផែនការនិងយុទ្ធសាស្ត្រ ដើម្បីធ្វើការតាមដាន វាយតម្លៃស្ថានភាពនៃការឆ្លងរាតត្បាតជំងឺកូវីដ-១៩ និងភាពស៊ាំសហគមន៍។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់តាមភារកិច្ចរៀងៗខ្លួន។

សូម ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

**ចម្លងជូន៖**

- គណៈប្រចាំការនៃ គ.ប.ក.
- គណៈប្រតិបត្តិនៃ គ.អ.ក.
- ឯកសារ-កាលប្បវត្តិ

ម៉ម ប៊ុនហេង